# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

TONLE SAP AUTHORITY

លេខ :..៦១១........អទស

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេស ដើម្បីកំណត់រៀបចំក្របខណ្ឌយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប នៃកម្មវិធីការអនុវត្តវាយតម្លៃសន្តិសុខទឹក ក្រោមកិច្ចសហប្រតិបត្តិការជំនួយគាំទ្រ ធនាគារពិភពលោក

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- បានឃើញសេចក្តីសម្រេចលេខ ៤៩៩ អទស ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេស ដើម្បីកំណត់រៀបចំក្របខណ្ឌយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប នៃកម្មវិធីការអនុវត្តវាយតម្លៃសន្តិសុខទឹក
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរទន្លេសាប

អគារលេខ ៥៧៦, ផ្លូវជាតិលេខ ២, សង្កាត់ ចាក់អង្រែក្រោម, ខណ្ឌ មានជ័យ, រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
#576, National Road No.2, Sangkat Chak Angre Krom, Khan Meanchey, Phnom Penh, Cambodia, Phone / Fax : (855) 23 727 454, Website: www.tonlesap.gov.kh

# សម្រេច

**ប្រការ ១.**_

ត្រូវបានកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេស ដើម្បីកំណត់រៀបចំក្របខណ្ឌយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប នៃកម្មវិធីការអនុវត្តវាយតម្លៃសន្តិសុខទឹក ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **ហ៊ែល** | **តូនី** | អនុប្រធានក្ដាប់រួម អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- លោក | **ឡុក** | **សីលា** | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ | អនុប្រធាន |
| ៣- លោក | **លឹម** | **ហេង** | អនុប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ | សមាជិក |
| ៤- លោក | **ណុំ** | **សោភារិទ្ធិ** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | សមាជិក |
| ៥- លោកស្រី | **ទេស** | **សុជាទី** | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ | សមាជិក |
| ៦- លោក | **សាយ** | **វិរៈ** | ប្រធានការិយាល័យរដ្ឋបាល | សមាជិក |
| ៧- លោក | **ផូ** | **សំណាង** | អនុប្រធានការិយាល័យបុគ្គលិក និងបណ្ដុះបណ្ដាល | សមាជិក |
| ៨- លោកស្រី | **យឹម** | **សម្ផស្ស** | អនុប្រធានការិយាល័យរដ្ឋបាល | សមាជិក |
| ៩- លោក | **អ៊ី** | **ណារ៉ែត** | អនុប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ | សមាជិក |
| ១០-លោក | **អៀ** | **ច័ន្ទរិទ្ធ** | អនុប្រធានការិយាល័យនីតិកម្ម | សមាជិក |
| ១១- លោក | **ភាន់** | **សម្បត្តិ** | អនុប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន | សមាជិក |
| ១២-លោកបណ្ឌិត | **អ៊ុក** | **សុវណ្ណារ៉ា** | ជំនួយការផ្ទាល់ឯកឧត្តមអនុប្រធានក្ដាប់រួម អាជ្ញាធរទន្លេសាប | សមាជិក |
| ១៣-លោក | **ឃិន** | **ឧត្តម** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៤-លោក | **អង់** | **សុភត្រ្តា** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៥- លោក | **ពេញ** | **សុខសិរីវឌ្ឍនៈ** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៦- លោក | **មិន** | **គុងយ៉ូ** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៧- លោក | **ឈួង** | **យឹង** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៨- លោក | **គុជ** | **សុខខេង** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៩- កញ្ញា | **វិសិដ្ឋ** | **សុជាតា** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ២០- កញ្ញា | **យឿត** | **ធីអិន** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |

**ប្រការ ២.**_

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលកិច្ចការបច្ចេកទេសជាមួយបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធ ប្រកបដោយស្មារតីបុរេសកម្ម ស្របតាមផែនការ នៃការចូលរួមរបស់ភាគីពាក់ព័ន្ធ សម្រាប់ការកសាងផែនការ និងវាយតម្លៃលើការវិនិច្ឆ័យសន្តិសុខទឹកទន្លេសាប
- សហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារធនាគារពិភពលោក World Bank Group,(WBG) ក្រសួងការបរទេសនិងពាណិជ្ជកម្ម Department of Foreign Affairs and Trade,(DFAT) និងអង្គការភាពជាដៃគូទឹកអូស្ត្រាលី Australian Water Partnership,(AWP) របស់ប្រទេសអូស្ត្រាលី ក្នុងការអនុវត្តការវាយតម្លៃលើការវិនិច្ឆ័យ សន្តិសុខទឹក ការកសាងសមត្ថភាពបច្ចេកទេស និងជំនាញ

- ចូលរួមពិនិត្យតាមដានលើវឌ្ឍនភាពសកម្មភាពការងារ និងរៀបចំសកម្មភាពការងារបន្ត បន្ទាប់ពីទទួលបានលទ្ធផលនៃការវាយតម្លៃលើការវិនិច្ឆ័យសន្តិសុខទឹក ការពិគ្រោះយោបល់ក្នុងវេទិកាពហុភាគីពាក់ព័ន្ធ និងការសម្រេចចិត្តរបស់អាជ្ញាធរទន្លេសាប
- ត្រួតពិនិត្យ និងគាំទ្រដល់ក្រុមការងារទីប្រឹក្សាបច្ចេកទេស ដែលធ្វើការវាយតម្លៃលើការវិនិច្ឆ័យ រួមជាមួយការកសាងផែនការ និងការសិក្សាបច្ចេកទេសដែលពាក់ព័ន្ធផ្សេងទៀត
- គាំទ្រដល់ដំណើរការការងារគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួល និងការរៀបចំឱ្យមានភាពប្រទាក់ក្រឡាគ្នាជាមួយគម្រោង/កម្មវិធីផ្សេងទៀតរបស់ធនាគារពិភពលោក និងក្រសួងការបរទេស និងពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលី ក៏ដូចជាសកម្មភាព/កម្មវិធីរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ
- ចូលរួមផ្ដល់យោបល់លើការសិក្សា និងរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់អាងបឹងទន្លេសាប
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារជូន ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប ដើម្បីពិនិត្យ សម្រេច និងផ្ដល់អនុសាសន៍ណែនាំ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនដោយ ឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប។

**ប្រការ ៣ ._**

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប ឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥._**

អនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង គ្រប់ប្រធាននាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃពុធ ១២កើតខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**ចៅ-ជេដ្ឋា**

**ចម្លងជូន ៖**

- ក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ